# ពិធីដង្ហែអ្នកតាព្រីងក្អែក និងជំនឿសុំទឹកភ្លៀង

ក្នុងសង្គមខ្មែរជំនឿលើអ្នកតានៅតែជាឫសគល់វប្បធម៌ដ៏សំខាន់ ដែលឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងមនុស្ស ធម្មជាតិ និងពិភពអរូបី។ ក្នុងចំណោមនោះ ពិធីបុណ្យឡើងអ្នកតា ឬហៅអ្នកតាព្រីងក្អែក ដែលជាទំនៀមរបស់ប្រជាពលរដ្ឋរស់នៅក្បែរជើងភ្នំបាសិត ប្រារព្ធដើម្បីសុំសេចក្តីសុខ និងសុំទឹកភ្លៀង គឺជាឧទាហរណ៍បង្ហាញពីទំនាក់ទំនងរវាងអ្នកស្រុក អ្នកតា និងទឹកភ្លៀង ពោលគឺទំនាក់ទំនងរវាងអ្នកតានិងរបរកសិកម្មរបស់អ្នកស្រុក។ តាមទម្លាប់ ពិធីនេះតែងប្រារព្ធមួយឆ្នាំម្តង នៅថ្ងៃ៤កើត ដល់ថ្ងៃ៥កើត ខែជេស្ឋ (ក្នុងឆ្នាំនេះត្រូវនឹងថ្ងៃទី២០ និងទី២១ ខែឧសភា ឆ្នាំ២០២៦) នៅលើកូនទួលតូចមួយកន្លែងហៅថា "ទួលអ្នកតាព្រីងក្អែក" ឬ "អ្នកតាគហេ" (រូបលេខ១)។[1] សូមបញ្ជាក់ថា ទីទួលអ្នកតាព្រីងក្អែកបានចុះក្នុងបញ្ជីទួលបុរាណនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈផងដែរ។



*រូបលេខ១ ទីទួលអ្នកតាព្រីងក្អែក ក្នុងថ្ងៃសូត្រមន្តឡើងអ្នកតា (ថ្ងៃទី១)*

[1] សូមអានៈ "ទំនៀមបុណ្យប្រចាំឆ្នាំនៅទួលអ្នកតាព្រីងក្អែក" លើគេហទំព័រ https://khmercivilization.ams.com.kh/detail/27843 (៣០ ឧសភា ២០២៣)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះប្រវត្តិនៃឈ្មោះអ្នកតានៅទីទួលនេះ ហាក់ដូចជាវិវត្តទៅតាមការកត់សម្គាល់របស់អ្នកស្រុក ដែលយកតាមទិដ្ឋភាពនៃខ្ទមអ្នកតាតាំងនៅក្រោមដើមព្រីង។ ប៉ុន្តែអ្នកខ្លះយល់ថា អ្នកតាព្រីងក្អែក ឬអ្នកតាគហេ គឺជាបុព្វបុរសនៅក្នុងរឿងព្រេងបុរាណខ្មែរ គឺរឿង "បក្សីចាំក្រុង"។ តាមសាច់រឿងដែលអ្នកស្រុកនៅចងចាំ និងមានកត់ត្រាក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៩ បញ្ជាក់ដោយសង្ខេបថា កាលពីព្រេងនាយមានស្តេចមួយអង្គបានឱ្យហោរាគន់គូរជោគជតារាសី។ ហោរាទាយថានឹងមានអ្នកដណ្តើមរាជ្យ។ ក្រោយមកស្តេចក៏បានបញ្ជាឱ្យគេតាមរក រហូតឃើញកុមារម្នាក់ដែលមានរូបកងចក្រនៅលើបាតដៃ ស្តេចក៏បញ្ជាឱ្យតាមសម្លាប់កុមារនោះ។ ក្នុងគ្រោះថ្នាក់នោះ ដោយសារបុណ្យបារមីក៏មានតាចាស់ម្នាក់ឈ្មោះតាគហេ បានពរកុមារនោះរត់គេចខ្លួនគ្រប់ច្រកល្ហក រហូតមកដល់ភ្នំបាសិត ហើយបានយកកុមារទៅលាក់ទុកក្នុងរូងភ្នំ។ បន្ទាប់មក ដើម្បីបង្វែងដានកុំឱ្យទ័ពស្តេចរកឃើញ តាគហេបានដើរឈានថយក្រោយ ពីរូងភ្នំរហូតមកដល់ទីទួលមួយ ដែលជាទីទួលអ្នកតាព្រីងក្អែកសព្វថ្ងៃនេះ។[2]

យោងតាមការសិក្សាស្រាវជ្រាវ និងសាកសួរចាស់ទុំបញ្ជាក់ថា តាំងពីដើមរៀងមកអ្នកតាព្រីងក្អែកពុំដែលដឹងថាមានរូបស្នង ឬមានកិច្ចបញ្ចូលរូប(ដាន់រូប)ឡើយ។ នៅឆ្នាំ ២០១៨ អ្នកស្រុកបានសាងសង់រូបសំណាកពីស៊ីម៉ងត៍ តម្កល់ក្នុងខ្ទមក្រោមដើមព្រីង (មានដើមពោធិធំមួយនៅពីមុខ)។ រូបចម្លាក់នោះមានទម្រង់មុខមាំ មានពុកមាត់ ពុកចង្កាចិញ្ចើមក្រាស់ អង្គុយពែនភ្នែន ដៃឆ្វេងដាក់លើក្បាលជង្គង់ ដៃស្តាំកាន់ដំបង សម្លៀកបំពាក់ពណ៌ខ្មៅ ហើយជារឿយៗអ្នកស្រុកច្រើនចូលមកថ្វាយឆ្នូតក្បាលពណ៌ក្រហម និងបង់កក្រណាត់ក្រហម (រូបលេខ២)។ ប៉ុន្តែនៅលើដើមព្រីង ខាងក្រោយខ្ទមនោះ ត្រង់មែកព្រីងធំដែលទោរលើខ្ទម គេបានឆ្លាក់ចេញជាទម្រង់រូបសំណាកបុរសម្នាក់ស្លៀកក្បិន លែងខ្លួនទទេ ដៃស្តាំកាន់ដំបង ដែលអ្នកស្រុកជឿថានេះក៏ជារូបតំណាងឱ្យអ្នកតាព្រីងក្អែកដែរ (រូបលេខ៣)។ នៅក្បែរខ្ទមនោះក៏មានសាលាបុណ្យមួយខ្នងសម្រាប់ប្រារព្ធកិច្ចខាងសាសនាសង់ឡើងតាំងពីឆ្នាំ២០១១។

---

[2] សូមអរគុណលោកតា អ៊ី អឹន ដែលបានផ្តល់ព័ត៌មានខាងលើ។ សូមអានបន្ថែម៖ ប្រជុំរឿងព្រេងខ្មែរភាគ៩ ទំ.៣៧-៤៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត





រូបលេខ២-៣ រូបសំណាកអ្នកតាព្រីងក្អែក

ដោយឡែកចំពោះពិធីដង្ហែអ្នកតា គឺជាពិធីសំខាន់នៅថ្ងៃទី២ ដែលប្រព្រឹត្តទៅនៅវេលាព្រឹកព្រលឹម ពោលគឺបន្ទាប់ពីប្រគេនចង្ហាន់ដល់ព្រះសង្ឃរួចរាល់។ ក្នុងពិធីដង្ហែនេះ គេសម្គាល់ឃើញយុវជនប្រុសស្រីតែងនាំគ្នាគូរមុខ និងតែងខ្លួនប្លែកៗ។ ការតុបតែងខ្លួននោះគេឃើញជាពិសេស គឺយុវជននិងកុមារ ដោយភាគច្រើនគេនិយមយកយកធ្យូងមកគូរមុខ និងលាបខ្លួនឱ្យខ្មៅឱ្យមានសភាពដូចមនុស្សកុលសម្ព័ន្ធ។ ទន្ទឹមនឹងនេះ មានក្រុមខ្លះតុបតែងខ្លួនជាតួអង្គផ្សេងៗដូចជា ឥសី ស្តេច អាមាត្យ ត្លុក យក្ស អ្នកគុននិយម ឬតុបតែងស្លៀកសម្លៀកបំពាក់រហែករយ៉ៃ ខ្លះកាន់ដំបង ដាវ ពូថៅ កាំបិត ដើមអំពៅ ឬចងមែកឈើជុំវិញចង្កេះ ហើយអ្នកខ្លះ តុបតែងខ្លួនជាជាតិសាសន៍ផ្សេងៗ ពុំកំណត់តួអង្គអ្វីជាក់លាក់ឡើយ ដើរដង្ហែដោយមានស្គរផៃយ៉ាំប្រគំនាំមុខយ៉ាងគគ្រឹកគគ្រេង និងមានក្រុមអ្នកជិះសេះនៅខាងមុខបំផុត។ ក្បួនដង្ហែនេះមានចម្ងាយផ្លូវជិត២គីឡូម៉ែត្រ ដង្ហែកាត់តាមភូមិឆ្ពោះទៅកាន់ទួលអ្នកតា។ ក្រុមមនុស្សដែលតែងខ្លួនចម្លែកៗទាំងនោះ ច្រើនតែធ្វើកាយវិការជាមនុស្សកំណាច ស្រែកធ្វើសំឡេងខ្លាំងៗ ហើយជារឿយៗគេធ្វើជាបន្លាចអ្នកស្រុក ជាពិសេសគឺបន្លាចក្មេងៗ។ ប៉ុន្តែពេលក្បួនដង្ហែដល់អ្នកភូមិតាមផ្ទះតែងហុចប្រាក់ខ្លះផងដែរ។ លុះក្បួនដង្ហែមកដល់ខ្ទមអ្នកតា គេនាំគ្នាចូលទៅអុជធូប និងរាំថ្វាយអ្នកតាយ៉ាងសប្បាយរីករាយកំដរដោយភ្លេងផៃយ៉ាំ(រូបលេខ២-១១)។ ទន្ទឹមនោះក្រុមអ្នកជិះសេះក៏យកសេះមកបង្ហាញមុខខ្ទមអ្នកតាដែរ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត


















រូបលេខ៨-១១ សកម្មភាពក្បួនដង្ហែតាមដងផ្លូវឆ្ពោះមកកាន់ខ្ទមអ្នកតាព្រើងក្អែក

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បន្ទាប់ពីក្បួនដង្ហែមកដល់ខ្ទមអ្នកតា និងរាំថ្វាយ ព្រមទាំងធ្វើកិច្ចបូជារួចហើយ គេនាំគ្នាហែជុំវិញខ្ទមអ្នកតាបីជុំ។ បន្ទាប់មក គេដង្ហែសង្សឹកទៅចោលឆ្ងាយ តាមដែលលោកអាចារ្យចង្អុលបង្ហាញ។ សោតឯសង្សឹកនោះគេធ្វើពីស្រទបចេកនិងដើមចេក ហើយគ្រឿងបូជាសង្សឹករួមមាន ស្រូវ ពោត សណ្តែក ល្ង អង្ករ និងប្រាក់បន្តិចបន្តួច។ បន្ទាប់ពីដើរប្រទក្សិណគ្រប់៣ជុំខ្ទមអ្នកតា  គេចាប់លើកសែងសង្សឹកចេញក្បួនបន្តទៅទិសព្វាយ័ព្យ។ សង្សឹកនោះមុននឹងទម្លាក់ចោល គេនាំគ្នាលើកឡើងខ្ពស់ហ៊ោកញ្ជ្រាវពីរ៣ដង ទើបទម្លាក់ចុះឲ្យខ្ចាត់ខ្ចាយ។ ក្មេងៗក៏ដណ្តើមយកប្រាក់ ឬស្រូវអង្ករនោះរៀងៗខ្លួន (រូបលេខ១២)។



រូបលេខ១២ កិច្ចដង្ហែសង្សឹកចោលនៅទិសព្វាយ័ព្យនៃខ្ទមអ្នកតា

អ្នកស្រុកនិយាយដោយខ្លីថា បំណងនិងអត្ថន័យនៃពិធីជាទំនៀមខាងលើ រៀបចំឡើងតាំងពីដូនតា ដើម្បីសុំសេចក្តីសុខសប្បាយដល់មនុស្សសត្វ និងជាពិសេសគឺសុំទឹកភ្លៀងពីលោកតាព្រើងក្អែក។ ប្រការត្រង់នេះហាក់ដូចជាសំខាន់ដែលត្រូវពិចារណា ដ្បិតភូមិស្រុកនេះដើមឡើយជាវាលស្រែល្វឹងល្វើយ អ្នកស្រុកប្រកបរបរធ្វើស្រែ ចិញ្ចឹមសេះ ចិញ្ចឹមគោក្របីជាកម្លាំងអូសទាញ។ ចំណែកឯការដង្ហែអ្នកតាដ៏គគ្រឹកគគ្រេង លាបខ្លួន

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ខ្មៅ គួរមុខមាត់ និងស្លៀកពាក់ខោអាវរហែក រយ៉ៃ ឬស្លៀកស្លឹកចេក ស្រដៀងទៅនឹងពួកមនុស្សព្រៃ ព្រាយ ឬខ្មោច ដែលទិដ្ឋភាពនេះហាក់ដូចជាស្រដៀងគ្នានឹងទំនៀម"បញ្ចៀសចង្រៃ" តែងប្រារព្ធឡើងក្នុងតំបន់បុរាណផ្សេងទៀតដូចជា តំបន់អង្គរ (សៀមរាប)[3] ឬកោះកេរ (ព្រះវិហារ)។ ការបន្ទាចក្មេងៗ និងការយកស្រូវអង្ករ ប្រាក់កាសដាក់ក្នុងសង្សឹក រួចយកទៅចោលនោះ គឺទំនងជានិមិត្តរូបនៃការបញ្ចៀសភាពអត់ឃ្លាន ជំងឺតម្កាត់ និងគ្រោះចង្រៃទាំងឡាយឱ្យចេញឆ្ងាយពីសហគមន៍ ដែលទម្លាប់នេះបានក្លាយជាវប្បធម៌អរូបីដ៏មានតម្លៃ និងជាចំណែកនៃចំណងសាមគ្គីភាពរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់។

## ឯកសារយោង


ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

២០០១, *ប្រជុំរឿងព្រេងខ្មែរ*, ភាគ៥, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ហៀន សុវណ្ណមរកត

២០២៣, "ទំនៀមបុណ្យប្រចាំឆ្នាំនៅទួលអ្នកតាព្រើងក្អែក", ផ្សាយលើតំណ https://khmercivilization.ams.com.kh/detail/27843 (៣០ ឧសភា ២០២៣)

អ៊ូ គង្គា, តូច សុកៈ, សោ ចន្ធា, ឆាន់ សុកិនី

២០២០, "បញ្ចៀសចង្រៃឧត្បាត", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១៥, ទំ.៣៣-៣៩, យសោធរ, ភ្នំពេញ


[3] អ៊ូ គង្គា, តូច សុកៈ, សោ ចន្ធា, ឆាន់ សុកិនី ២០២០: ៣៣-៣៩